**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦៤ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំសំណើធ្វើវិសោធនកម្មច្បាប់ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



www.pheakdeylaw.com

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំសំណើធ្វើវិសោធនកម្មច្បាប់ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. | ឯកឧត្តម **យឹម ឆៃលី** | ឧបនាយករដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣. | ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៤. | ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ជាសមាជិក |
| ៥. | ប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី | | ជាសមាជិក |
| ៦. | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ០១រូប | | ជាសមាជិក |
| ៧. | រដ្ឋលេខាធិការក្រសួងការពារជាតិ០១រូប | | ជាសមាជិក |
| ៨. | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី០១រូប | | ជាសមាជិក |
| ៩. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ០១រូប | | ជាសមាជិក |
| ១០. | រដ្ឋលេខាធិការក្រសួងកិច្ចការនារី០១រូប | | ជាសមាជិក |
| ១១. | រដ្ឋលេខាធិការក្រសួងយុត្តិធម៌០១រូប | | ជាសមាជិក |
| ១២. | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់០១រូប | | ជាសមាជិក |
| ១៣. | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម០១រូប | | ជាសមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ដឹកនាំតម្រង់ទិសផ្នែកនយោបាយសម្រាប់ការសិក្សាស្រាវជ្រាវ ការពិគ្រោះយោបល់ និងការរៀបចំសំណើធ្វើវិសោធនកម្មច្បាប់ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ ដោយធានាឲ្យមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រាយការណ៍ជូនរាជរដ្ឋាភិបាលជាប្រចាំអំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណើដំណោះស្រាយនានាពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ។

**ប្រការ ៣.-**

ប្រធានគណៈកម្មការអាចអញ្ជើញប្រធានស្ថាប័ន អង្គភាព មន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធដទៃទៀតឲ្យចូលរួមកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។



www.pheakdeylaw.com

**ប្រការ ៤.-**

គណៈកម្មការនេះអាចបង្កើតក្រុមការងារ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមការចាំបាច់។

ក្នុងការបំពេញការងាររបស់ខ្លួន គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មក ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> ÷**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*



www.pheakdeylaw.com